## ២.៦ ការចូលរៀនដោយសមធម៌ គុណភាព និង ប្រសិទ្ធភាពអប់រំនៅឧត្តមសិក្សា

### វត្ថុបំណង និង យុត្តិកម្ម

អនុវិស័យអប់រំឧត្តមសិក្សា គឺបន្តផ្តល់ និងពង្រីកការចូលរៀននៅឧត្តមសិក្សា ទន្ទឹមនឹងនោះក៏ត្រូវគិតគូរអំពីគុណភាពផងដែរ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ សង្គម និងសេដ្ឋកិច្ចកម្ពុជា នៅក្នុងផ្នែកអភិវឌ្ឍបញ្ញា និងការផ្តល់ធនធានមនុស្ស ។ ការចូលរៀនរបស់និស្សិតមកពីគ្រួសារក្រីក្រ នឹងត្រូវបានដោះស្រាយតាមរយៈការផ្តល់អាហារូបករណ៍សម្រាប់សិស្សពូកែ ជាពិសេសនិស្សិតស្រី ។ អាទិភាពមួយចំនួនត្រូវបានផ្តល់ដល់និស្សិតដែល ចុះឈ្មោះសម្រាប់ជំនាញពាក់ព័ន្ធតិចតួចទៅនឹងទីផ្សារ និងមានប្រយោជន៍ច្រើនចំពោះសង្គម (socially benefitcial programs) ជាពិសេសផ្នែកអប់រំ សុខាភិបាល កសិកម្ម វិទ្យាសាស្ត្រ និង គណិតសាស្ត្រ ។

### អាំងឌីកាទ័រ និង ចំណុចដៅគន្លឹះ

- បង្កើនការចុះឈ្មោះចូលរៀនជាទូទៅ នៅគ្រឹះស្ថានឧត្តមសិក្សានានា ពី ៤៦.៨៤៥ នាក់ នៅឆ្នាំសិក្សា ២០០៤/០៥ ទៅ ៩០.០០០ នាក់ ក្នុងនោះ ៤០% ជានិស្សិតស្រី នៅឆ្នាំ ២០១០ ។
- បង្កើនការចុះឈ្មោះចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈពី ៧.៩៦៣ នាក់ នៅឆ្នាំសិក្សា ២០០៤/០៥ ទៅ ៣៦.០០០ នាក់ ក្នុងនោះ ៣៣% ជានិស្សិតស្រី នៅឆ្នាំ ២០១០ ។
- បង្កើនការចុះឈ្មោះចូលរៀនផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងគណិតសាស្ត្រ នៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន អោយបាន ២០.០០០ នាក់ នៅឆ្នាំ ២០១០ ។
- រៀបចំលក្ខណៈវិនិច្ឆ័យលំអិតជាមូលដ្ឋានសម្រាប់បង្កើតគ្រឹះស្ថានឧត្តមសិក្សានៅឆ្នាំ ២០០៦ ។
- ពិនិត្យឡើងវិញគ្រឹះស្ថានឧត្តមសិក្សានានាដើម្បីធានាថា គ្រឹះស្ថានឧត្តមសិក្សាទាំងនោះ គោរពតាមគោលការណ៍ និងលក្ខណៈវិនិច្ឆ័យជាមូលដ្ឋាននៃការបង្កើតគ្រឹះស្ថានឧត្តមសិក្សា នៅឆ្នាំ ២០០៧ ។

### យុទ្ធសាស្ត្រ និង វិសាលភាព

យុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការអប់រំឧត្តមសិក្សា គឺពង្រីក និងពង្រឹងភាពជាដៃគូសាធារណៈ/ឯកជន[១] ដើម្បីធ្វើអោយសម្រេចបាននូវការចូលរៀនប្រកបដោយសមធម៌ និងកែលំអគុណភាពក្នុងការគ្រប់គ្រង និងផ្តល់ការអប់រំនៅកម្រិតនេះ ។ តួនាទីសំខាន់របស់ក្រសួងសម្រាប់កំរិតសិក្សានេះមានពីរគឺ ទីមួយ ធានាការចូលរៀនប្រកបដោយសមធម៌ តាមរយៈការផ្តល់វគ្គសិក្សាជ្រើសរើសមួយចំនួននៅក្នុងគ្រឹះស្ថាន

---

[១] *ការចូលរួមពីវិស័យសម្រាប់ភាពជាដៃគូ គឺជាការផ្តល់វគ្គសិក្សាជ្រើសរើសមួយចំនួន អាហារូបករណ៍សម្រាប់និស្សិត ការធានាគុណភាព និងការទទួលស្គាល់គ្រឹះស្ថានសិក្សា ។ ការចូលរួមពីផ្នែកឯកជន ជាបឋមគឺជាការផ្តល់វគ្គសិក្សាឯកជន ប៉ុន្តែក៏ពង្រីកអោយមានការគាំទ្រ និងសហប្រតិបត្តិការនៅផ្នែកមួយចំនួនដូចជា អាហារូបករណ៍ផ្នែកឯកជន វគ្គសិក្សាផ្លាស់ប្តូរបទពិសោធន៍ (Work-based sandwich) អាហារូបករណ៍សម្រាប់នាយកដ្ឋាន ឬគ្រឹះស្ថានសិក្សា អាហារូបករណ៍សម្រាប់ការសិក្សាស្រាវជ្រាវ និងការចែករំលែកធនធាន (សាលសន្និសិទ្ធ អន្តេវាសិកដ្ឋាន បន្ទប់ពិសោធន៍) ។*

សិក្សាសាធារណៈ និងការផ្តល់អាហារូបករណ៍ដល់និស្សិតពូកែមួយចំនួន ។ ទីពីរ ធ្វើទំនាក់ទំនងជាមួយគណៈកម្មាធិការទទួលស្គាល់គុណភាពនៃកម្ពុជា (ACC) ដើម្បីពិនិត្យ និងធានាគុណភាពអប់រំឧត្តមសិក្សាដែលអាចទទួលយកបាន ទាំងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន[២] ។ កម្មវិធីនេះនឹងផ្សារភ្ជាប់ទៅនឹងការស្នើថវិកាអភិវឌ្ឍន៍ជាមូលធនសម្រាប់ការអប់រំឧត្តមសិក្សា និងដាក់អោយអនុវត្តគំរោងខ្ចីប្រាក់សម្រាប់និស្សិតឧត្តមសិក្សាតាមដែលអាចធ្វើទៅបាន ។ ក្រសួងក៏មានគោលដៅពង្រីកការបង្រៀនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយបង្កើនគ្រូបង្រៀនផ្នែកនេះនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយចំនួន ។

**កម្មវិធី និង សកម្មភាពចម្បង១**

- បង្កើនគុណភាពការអប់រំឧត្តមសិក្សា ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ តាមរយៈការផ្តល់ថវិកាសម្រាប់ដំណើរការគ្រឹះស្ថានឧត្តមសិក្សា និងសកម្មភាពស្រាវជ្រាវចំពោះគ្រឹះស្ថានឧត្តមសិក្សា ក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និង កីឡា និងក្រសួងនានាដែលគ្មានកម្មវិធីសកម្មភាពជាអាទិភាព ។ ថវិកាទាំងនេះ ត្រូវផ្អែកលើចំនួននិស្សិតអាហារូបករណ៍ និង ចំណាយសម្រាប់កម្មវិធី ។
- បង្កើនចំនួននិស្សិតអាហារូបករណ៍ ដោយផ្តោតជាសំខាន់លើនិស្សិតស្រី និស្សិតក្រីក្រ និស្សិតពិការ និងនិស្សិតមកពីតំបន់ដាច់ស្រយាល/មានសេវាមិនគ្រប់គ្រាន់ ដើម្បីចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សាតាមរយៈការផ្តល់ថវិកាសម្រាប់គាំទ្រ និងដំណើរការគ្រឹះស្ថានសិក្សា ។ គ្រឹះស្ថានសិក្សាអាទិភាព គឺគ្រឹះស្ថានឧត្តមសិក្សាសាធារណៈដែលផ្តល់កម្មវិធីសិក្សាមានប្រយោជន៍ចំពោះសង្គម ជាពិសេសផ្នែកអប់រំ សុខាភិបាល កសិកម្ម វិទ្យាសាស្ត្រ និង គណិតសាស្ត្រ ។
- កែលំអគុណភាពសម្ភារៈបង្រៀន និងរៀន និងពង្រីកកម្មវិធីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងគណិតវិទ្យា ទាំងនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ។ កម្មវិធីទាំងនេះត្រូវផ្សារភ្ជាប់ទៅនឹងមូលនិធិអភិវឌ្ឍន៍សម្ភាររូបវ័ន្តឧត្តមសិក្សា ដែលបានស្នើឡើងនៅក្នុងកម្មវិធីមូលធន ។
- សាងសង់អន្តេវាសិកដ្ឋានសម្រាប់និស្សិតមកពីខេត្ត-ក្រុង ពិសេសនិស្សិតស្រី ។
- បង្កើតគំរោងឥណទានកម្ចីសម្រាប់និស្សិត ។
- បង្កើតគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនៅតាមតំបន់ ជាជំហាន១ ។
- គាំទ្រដល់ការប្រើប្រាស់សៀវភៅសិក្សាគោលជាភាសាខ្មែរ នៅគ្រឹះស្ថានឧត្តមសិក្សា ។
- ពិនិត្យតាមដាន ពិនិត្យឡើងវិញ និងវាយតម្លៃក្របខ័ណ្ឌកម្មវិធីសិក្សាសម្រាប់គ្រឹះស្ថានឧត្តមសិក្សា ។
- រៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ឋានៈសាស្ត្រាចារ្យនៅតាមគ្រឹះស្ថានឧត្តមសិក្សា ដោយផ្អែកលើគុណវុឌ្ឍិ បទពិសោធន៍ និងសមត្ថភាព ។

---

[២] *បច្ចុប្បន្ន តួនាទី និងការទទួលខុសត្រូវពិតប្រាកដ របស់អង្គភាពទាំងពីរ ស្ថិតនៅក្រោមការចរចា ។*

- ពង្រឹងដំណើរការចុះឈ្មោះចូលរៀន ដោយផ្អែកលើលទ្ធផលប្រលងថ្នាក់ទី ១២ ។
- ពិនិត្យឡើងវិញលក្ខណៈវិនិច្ឆ័យជ្រើសរើស និងរូបមន្តផ្តល់ហិរញ្ញប្បទានសម្រាប់គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើថ្លៃសិក្សា និងតម្រូវការ ព្រមទាំងកែលំអការគ្រប់គ្រង និងអភិបាលកិច្ចនៅគ្រឹះស្ថានឧត្តមសិក្សា តាមរយៈការបង្កើនតម្លាភាព និងគណនេយ្យភាពលើហិរញ្ញប្បទានទាំងអស់សម្រាប់គ្រឹះស្ថានឧត្តមសិក្សា ជាមួយការរួមចំណែករបស់រាជរដ្ឋាភិបាល ការបង់ថ្លៃរបស់និស្សិត និងការចូលរួមចំណែករបស់ផ្នែកឯកជនជាសាច់ប្រាក់ និងសម្ភារៈ ។
- បង្កើនកាលានុវត្តភាពសម្រាប់និស្សិតក្នុងការផ្ទេរការសិក្សា និងបន្តការសិក្សារវាងគ្រឹះស្ថានឧត្តមសិក្សាឯកជន និងសាធារណៈ តាមរយៈការទទួលស្គាល់គុណភាពអប់រំ និងការរៀបចំផ្ទេរក្រេឌីត ។

### ការគ្រប់គ្រង និង ការពិនិត្យតាមដានកម្មវិធី

ថវិកាគាំទ្រ និងដំណើរការគ្រឹះស្ថាន ត្រូវគ្រប់គ្រងផ្ទាល់ដោយគ្រឹះស្ថានឧត្តមសិក្សាដែលបានជ្រើសរើសស្របទៅតាមការគ្រោងបម្រុងសម្រាប់អាហារូបករណ៍ប្រចាំឆ្នាំ ។ នាយកដ្ឋានឧត្តមសិក្សា នឹងទទួលខុសត្រូវសម្រាប់ការធានាគុណភាព និងការពិនិត្យតាមដាន ។

នាយកដ្ឋានឧត្តមសិក្សាទទួលខុសត្រូវក្នុងការរៀបចំផែនការប្រចាំឆ្នាំ ដោយរាប់បញ្ចូលកម្មវិធីចំណាយសម្រាប់អាហារូបករណ៍ និងការបែងចែកថវិកាទៅដល់គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ។ គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវរៀបចំផែនការការងារប្រចាំឆ្នាំ រួមមានការកែលំអចំណុចដៅ ផែនការសកម្មភាព និងគំរោងថវិកាសម្រាប់ការប្រើប្រាស់មូលនិធិទាំងនេះនៅតាមមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់នីមួយៗ រួចដាក់សុំការអនុម័តតាមរយៈ BMC នៃនាយកដ្ឋានឧត្តមសិក្សា ។ មូលនិធិរបស់កម្មវិធី ត្រូវគ្រប់គ្រងដោយផ្ទាល់ដោយគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ។

នាយកដ្ឋានឧត្តមសិក្សា នឹងធ្វើការពិនិត្យតាមដានផលប៉ះពាល់ និងការរីកចម្រើន ដែលផ្តោតការយកចិត្តទុកដាក់លើវត្តមានរបស់និស្សិត ការសិក្សា និងការផ្តល់មូលនិធិផ្សេងទៀតសម្រាប់អាហារូបករណ៍ ព្រមទាំងពិនិត្យតាមដានផ្នែកបច្ចេកទេសនៃ BMC របស់គ្រឹះស្ថានសិក្សា ព្រមទាំងប្រសិទ្ធភាពនៃការបំពេញការងាររបស់គ្រឹះស្ថាន តាមរយៈការចុះពិនិត្យពីរដងក្នុងមួយឆ្នាំ ។ របាយការណ៍ពិនិត្យតាមដាន ត្រូវដាក់ជូនទៅថ្នាក់ដឹកនាំក្រសួង តាមរយៈ BMC របស់នាយកដ្ឋានឧត្តមសិក្សា ។ របាយការណ៍ប្រចាំឆ្នាំ ត្រូវរួមបញ្ចូលវិធានការសម្រាប់ការបំពេញការងារដែលបានស្នើឡើងដោយគ្រឹះស្ថានឧត្តមសិក្សា សម្រាប់ការកែលំអចំណុចដៅទាំងឡាយនៅក្នុងផែនការការងាររបស់ខ្លួន ។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំគំរូតាងសវនកម្មបច្ចេកទេស និងគំរូតាងសវនកម្មហិរញ្ញវត្ថុផ្ទៃក្នុង ។

ក្រសួងអប់រំ យុវជន និង កីឡា បន្តអនុវត្តគោលនយោបាយវិមជ្ឈការក្នុងការគ្រប់គ្រងផ្នែកឧត្តមសិក្សាតាមរយៈការជំរុញគ្រឹះស្ថានឧត្តមសិក្សានីមួយៗអោយបង្កើតប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងរបស់ខ្លួនអោយ

មានតម្លាភាព និងគណនេយ្យភាព ។ លក្ខណៈពិសេសដែលរំពឹងទុកគឺ រៀបចំអោយមានក្រុមប្រឹក្សាភិបាលនៅតាមគ្រឹះស្ថានឧត្តមសិក្សានីមួយៗ និងពិនិត្យឡើងវិញការទទួលខុសត្រូវរបស់នាយកដ្ឋានឧត្តមសិក្សា ក្នុងការរៀបចំគោលនយោបាយ ផែនការ និងការពិនិត្យតាមដាន ដើម្បីធានាគុណភាព ប្រសិទ្ធភាព និងការចូលរៀននៅឧត្តមសិក្សាប្រកបដោយសមធម៌ ។ ស្របទៅនឹងទិសដៅនេះ ក្រសួងអប់រំ យុវជន និង កីឡា នឹងបង្កើតចក្ខុវិស័យ និងផែនការសកម្មភាពផ្នែកឧត្តមសិក្សា ។ ការរៀបចំចក្ខុវិស័យ និងផែនការសកម្មភាពនឹងត្រូវបញ្ចប់នៅឆ្នាំ ២០០៦ ។

## ផែនការហិរញ្ញវត្ថុ

ផែនការហិរញ្ញវត្ថុសម្រាប់បង្កើនការចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ត្រូវផ្អែកលើថវិកាគាំទ្រ និងដំណើរការសម្រាប់គ្រឹះស្ថានសិក្សានីមួយៗ ។

*តារាងទី៦ : ការកែលំអគុណភាព ប្រសិទ្ធភាព និង សមធម៌នៃការចូលរៀននៅឧត្តមសិក្សា*

| សកម្មភាព | ចំណាយគិតជាលានរៀល | | | | |
|---|---|---|---|---|---|
| | 2006 | 2007 | 2008 | 2009 | 2010 |
| ១- ថវិកាសម្រាប់គាំទ្រ និងដំណើរការគ្រឹះស្ថានសិក្សា | 5,340 | 5,810 | 6,300 | 6,770 | 7,240 |
| ២- ថវិកាសម្រាប់ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និង គុណភាពអប់រំឧត្តមសិក្សា | 160 | 190 | 200 | 230 | 260 |
| **ធនធានសរុប** | **5,500** | **6,000** | **6,500** | **7,000** | **7,500** |

## តម្រូវការកសាងសមត្ថភាព

- លើកកំពស់សមត្ថភាពគ្រូបង្រៀននៅឧត្តមសិក្សា រួមមានការបំប៉នក្នុងប្រទេស និងសកម្មភាពស្រាវជ្រាវ ។
- កសាងសមត្ថភាពសម្រាប់ភាពជាអ្នកដឹកនាំ និងការពិនិត្យតាមដានការបំពេញការងារជាយុទ្ធសាស្ត្រនៅនាយកដ្ឋានឧត្តមសិក្សា ។
- គាំទ្រដល់ការពង្រឹងបន្ថែមលើការរៀបចំផែនការ កិច្ចបញ្ជិការគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ព្រមទាំងការផ្តល់សម្ភារបរិក្ខារសម្រាប់ប្រព័ន្ធព័ត៌មាន និងសម្ភារៈផ្សេងៗទៀត ។
- គាំទ្រប្រតិបត្តិការរបស់នាយកដ្ឋានឧត្តមសិក្សា ក្នុងការវិភាគ និងការរៀបចំគោលនយោបាយ ព្រមទាំងការពិនិត្យតាមដាន ដើម្បីកែលំអការចូលរៀនដោយសមធម៌ គុណភាព និងការគ្រប់គ្រងស្ថាប័នផ្សារភ្ជាប់ទៅនឹងការបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំឧត្តមសិក្សា ។